# សេចក្ដីថ្លែងការណ៍រួម

## សាលាឧទ្ធរណ៍បញ្ជាអោយមានការដោះលែង លោក ម៉ម សូណង់ដូ កាន់ សុវណ្ណ និងលោក ទូច រាម

*រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣* - យើងខ្ញុំទាំងអស់គ្នា ជាក្រុមអង្គការសង្គមស៊ីវិលដូចរាយនាមខាងក្រោម សូមស្វាគមន៍ចំពោះសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍នៅក្នុងថ្ងៃនេះ លើការដោះលែងប្រធានស្ថានីយ៍វិទ្យុឯករាជ្យ លោក ម៉ម សូណង់ដូ និងសហភាគីចុងចោទពីរនាក់ផ្សេងទៀត ទូច រាម និងកាន់ សុវណ្ណ ប៉ុន្តែសូមរំលឹកថា នៅមានរយៈពេលច្រើនសម្រាប់ការស្ដារឡើងវិញនូវលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជាមុននឹងការបោះឆ្នោតសភាជាតិ ដែលនឹងប្រព្រឹត្តិទៅនៅខែកក្កដា ខាងមុខនេះ។

លោក ម៉ម សូណង់ដូ ក៏ជាប្រធានរបស់អង្គការមិនមែនរដ្ឋាភិបាលមួយ ដែលមានឈ្មោះថា សមាគមអ្នកប្រជាធិបតេយ្យត្រូវបានទទួលការកាត់ទោសក្នុងខែតុលា ឆ្នាំ២០១២ ពីបទដឹកនាំបង្កើតតំបន់អបគមន៍ប្រឆាំងរាជរដ្ឋាភិបាល ហើយត្រូវបានផ្ដន្ទាទោសអោយជាប់ពន្ធធនាគាររយៈពេល ២០ឆ្នាំ។ ប៉ុន្តែយោងតាមសំណើរសុំដ៏ចម្លែករបស់ព្រះរាជអាជ្ញា អំឡុងពេលសវនាការសាលាឧទ្ធរណ៍។ ក្នុងថ្ងៃនេះ សាលាឧទ្ធរណ៍បានសម្រេចលើកលែងការចោទប្រកាន់ពីបទបង្កើតតំបន់អបគមន៍ទៅជាបទល្មើសរុករានព្រៃឈើខុសច្បាប់ទៅវិញក្រោមមាត្រា ៩៧ ចំនុចទី ៦ នៃច្បាប់ព្រៃឈើ។ តុលាការក៏បានកាត់បន្ថយទោសរបស់លោកមកត្រឹមតែ ៥ឆ្នាំ ហើយ ៨ខែ ទោសនៅក្នុងពន្ធនាគារ ហើយទោសដែលនៅសល់ត្រូវបានព្យួរ។

លោក កាន់ សុវណ្ណ និងលោក ទូច រាម ត្រូវបានសាលាឧទ្ធរណ៍តំកល់ទុកសាលក្រមរបស់តុលាការដំបូងរាជធានីភ្នំពេញចំនួន ៣ឆ្នាំ និង៥ឆ្នាំ ប៉ុន្តែបានជាប់ទោសរយៈពេល ១០ខែ ហើយទោសដែលនៅសល់ត្រូវបានព្យួរ។

អ្នកទាំងបី ត្រូវបានរំពឹងថានឹងត្រូវបានដោះលែងនៅថ្ងៃសុក្រ។

លោក យ៉េង វីរៈ នាយកប្រត្តិបត្តិនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍បានមានប្រសាសន៍ថា "យើងស្វាគមន៍ចំពោះសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ ដែលបានធ្វើកាដោះលែងលោក ម៉ម សូណង់ដូ និងសហចុងចោទពីរនាក់ទៀត ក៏ប៉ុន្តែយើងមិនអាចនិយាយបានទេថា យុត្តិធម៌ត្រូវបានផ្ដល់អោយពួកគាត់យ៉ាងពេញលេញ។ ពួកគាត់នូវតែជាអ្នកមានទោស។ មិនមានភស្តុតាងជាក់លាក់អ្វីមួយ ដែលអាចធ្វើការចោទប្រកាន់ និងដាក់ទោសទៅលើអ្នកទាំងបីនាក់បានឡើយ ហើយការបំភិតបំភ័យនេះ អាចជះឥទ្ធិពលអវិជ្ជមានដ៏យូរអង្វែង។

លោក ម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួន នៅថ្ងៃទី១២ ខែកក្កដា ហើយត្រូវបានចោទប្រកាន់ដំបូង ពីបទផ្តួចផ្តើមគំនិត "បង្កើតចលនាអបគមន៍" ក្នុងខេត្តក្រចេះ។ ព្រះរាជអាជ្ញា បានលើកហេតុផល ដោយគ្មានភស្តុតាងច្បាស់លាស់ថា តំបន់នោះ គឺមានទីតាំងក្នុងភូមិប្រម៉ា ខេត្តក្រចេះ ហើយត្រូវបាន ប្រជាពលរដ្ឋជាច្រើននាក់ ដែលប្រដាប់ដោយអាវុធព្យាយាមប្រឆាំងនឹងអាជ្ញាធរក្នុងគោលបំណង បង្កើតរដ្ឋឯករាជ្យផ្ទាល់ខ្លួន។ តាមការពិត ប្រពលរដ្ឋពាក់ព័ន្ធជាមួយនឹងជម្លោះដីធ្លីកំពុងបន្តដំរ៉ាំរ៉ៃជា មួយក្រុមហ៊ុនកាសូទីម ដែលកាន់កាប់ដីសម្បទានទំហំ ១៥,០០០ ហិកតា នៅក្បែរភូមិ។

នៅខែឧសភា កងកម្លាំងប្រដាប់អាវុធរដ្ឋរាប់រយនាក់ បានធ្វើការវាយលុកចូលក្នុងភូមិ ហើយធ្វើ ការបណ្តេញប្រជាពលរដ្ឋជាច្រើនរយនាក់។ កុមារី ហេង ចន្ថា អាយុ ១៤ ឆ្នាំម្នាក់ ត្រូវបានបាញ់សម្លាប់ ដោយកងកម្លាំងរបស់រដ្ឋក្នុងអំឡុងពេលប្រត្តិបត្តិការណ៍បណ្តេញចេញដោយបង្ខំ។ អាជ្ញាធរ នូវតែ ប្រកាន់ជំហរមិនព្រមបើកការស៊ើបអង្កេតលើករណីស្លាប់របស់កុមារី ចន្ថា ដោយលើកឡើងថា វាជា ឧបទ្ទវហេតុ។

អ្នកនាង ណាលី ពីឡូក នាយិកាអង្គការលីកាដូ បានមានប្រសាសន៍ថា "នេះប្រហែលជាអំពើ អយុត្តិធម៌ដ៏ខ្លាំងណាស់សម្រាប់ព្រឹត្តិការណ៍ដែលកើតឡើងក្នុងខេត្តក្រចេះ។ លោក ម៉ម សូណង់ដូ និង សហចុងចោទបានចំនាយពេលជាច្រើនខែក្នុងពន្ធនាគារលើការចោទប្រកាន់ដោយគ្មានមូលហេតុ។ ប៉ុន្តែឃាតករដែលសម្លាប់កុមារី ហេង ចន្ថា មិនបានចំនាយពេលសូម្បីតែមួយថ្ងៃនៅក្នុងពន្ធនាគារ ឡើយ។ អាជ្ញាធរ មិនធ្លាប់ទាំងធ្វើការស៊ើបអង្កេតលើករណីបាញ់សម្លាប់នោះផងដែរ។

ទោះបីជា លោក សូណង់ដូ ត្រូវបានគេចោទប្រកាន់ជាអ្នកផ្តួចផ្តើមគំនិតបង្កើតចលនា អបគមន៍ក្នុងខែឧសភា ក៏ដោយ តែដីកាចាប់ខ្លួនរបស់លោកមិនត្រូវបានចេញមុនថ្ងៃ នៃការចេញ ផ្សាយរបាយការណ៍ក្នុងថ្ងៃទី២៥ ខែមិថុនា របស់តុលាឧក្រិដ្ឋកម្មអន្តរជាតិ (ICC) ក្នុងទីក្រុងឡាអេ ប្រទេសហូឡង់។ របាយការណ៍នោះ និយាយអំពីការដាក់ពាក្យបណ្តឹងរបស់ចលនាអំណាចពលរដ្ឋខ្មែរ ទៅកាន់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលធ្វើកាចោទប្រកាន់មន្ត្រីរដ្ឋាភិបាលរបស់ប្រទេសកម្ពុជាពីបទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានពាក់ព័ន្ធជាមួយនឹងបញ្ហាដីធ្លីក្នុងប្រទេសកម្ពុជា។

២៤ ម៉ោង បន្ទាប់ពីកាចេញផ្សាយតាមរលកធាតុអាកាសជាលើកដំបូងអំពីរបាយការណ៍របស់ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ប្រមុខរាជរដ្ឋាភិបាល បានបញ្ជាជាសាធារណៈអោយមានកាចាប់ខ្លួន លោក ម៉ម សូណង់ដូ។

លោក ប៉ា ងួនទៀង នាយកមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) បាន មានប្រសាសន៍ថា "ចាប់តាំងពីថ្ងៃដំបូងមករហូតដល់ថ្ងៃចេញសាលដីការបស់សាលាឧទ្ធរណ៍ យើង ឃើញថា ករណីនេះ គឺជាករណីដែលមានចរិកជាករណីនយោបាយ"។

អាជ្ញាធរកម្ពុជា បានប្រឈបមុខជាមួយនឹងអន្តរាគមន៍យ៉ាងខ្លាំងពីសំណាក់ជាតិ និងសហគមន៍ អន្តរជាតិ សូមឲ្យមានការដោះលែង លោក សូណង់ដូ បន្ទាប់ពីលោកត្រូវបានចោទប្រកាន់ក្នុងខែ

តុលា។ ក្នុងចំនោមអ្នកដែលធ្វើការទាមទារអោយមានការដោះលែង លោក សូណង់ដូ ក៏មានលោក ប្រធានាធិបតីសហរដ្ឋអាមេរិក ប៉ារ៉ាក់ អូប៉ាម៉ា អតីតរដ្ឋមន្ត្រីក្រសួងការបរទេសរបស់សហរដ្ឋ អាមេរិក អ្នកស្រី ហ៊ីលឡារី គ្លីនតុន និងនាយករដ្ឋមន្ត្រីសបារាំង លោក Jean-Marc Ayrault ។ លោក សូណង់ដូ មានសញ្ជាតិពីរ គឺ ខ្មែរ និងបារាំង។

លោក វ៉ន ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) បាន មានប្រសាសន៍ថា "ការដោះលែង លោក ម៉ម សូណង់ដូ និងសហចុងចោទរបស់លោកទាំងពីរ គឺជា ជំហានដ៏សំខាន់ទៅកាន់ការស្តារលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជា ប៉ុន្តែសហគមន៍អន្តរជាតិ គួរចាំថា ប្រធានបក្សជំទាស់នៅតែស្ថិតក្នុងការនិរទេសខ្លួននៅឡើយ។ បញ្ហានេះ បង្ហាញអោយមានការ ព្រួយបារម្ភយ៉ាងខ្លាំងសម្រាប់កាបោះឆ្នោតនាពេលខាងមុខ។

*មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)*
*សមាគមមន្ត្រីរាជការកម្ពុជា (CICA)*
*សហព័ន្ធសហជីពកម្មករចំនីអាហារ និងសេវាកម្មកម្ពុជា (CFSWF)*
*សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)*
*មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្មករកម្ពុជា (CWCD)*
*បណ្តាញយុវជនកម្ពុជា (CYN)*
*សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)*
*មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)*
*សមធម៌កម្ពុជា (EC)*
*ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF)*
*សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)*
*សមាគមធាងត្នោត (STT)*

## *សម្រាប់ពត៌មានបន្ថែម សូមទាក់ទង:*

- លោក យ៉េង វីរៈ នាយកប្រត្តិបត្តិនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍
  ទូរស័ព្ទ៖ ០១២ ៨០១ ២៣៥
- លោក អំ សំអាត អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេត នៃអង្គការ លីកាដូ
  ទូរស័ព្ទ៖ ០១២ ៣២៧ ៧៧០